# ថ្នាំបង្ការជំងឺ COVID-19 - សំណួរដែលបានសួរជាញឹកញាប់
## ការទទួលចាក់ថ្នាំបង្ការ

### តើខ្ញុំអាចចាក់ថ្នាំបង្ការបានដោយរបៀបណា?

ថ្នាំបង្ការអាចរកបាននៅទីតាំងរាប់រយកន្លែងនៅទូទាំងខោនធី LA រួមមានគ្លីនិក ឱសថស្ថាន កន្លែងធ្វើការ សាលារៀន កន្លែងគោរពបូជា និងទីតាំងតាមសហគមន៍ផ្សេងៗទៀត។ ការចាក់ថ្នាំបង្ការនៅតាមផ្ទះក៏មានផ្តល់ជូនផងដែរសម្រាប់មនុស្សដែលមិនអាចធ្វើដំណើរចេញពីផ្ទះបាន។ ទីតាំងជាច្រើនមិនតម្រូវឱ្យធ្វើការណាត់ជួបទេ។

ដើម្បីទទួលថ្នាំបង្ការ សូមចូលទៅកាន់គេហទំព័រ VaccinateLACounty.com ហើយជ្រើសរើស "ចុចនៅទីនេះដើម្បីទទួលចាក់ថ្នាំបង្ការ" (Click Here to Get Vaccinated) ដើម្បីស្វែងរកទីតាំងមួយ ឬ ស្នើសុំ ការចាក់ថ្នាំបង្ការតាមផ្ទះ។ ប្រសិនបើអ្នកត្រូវការជំនួយ អ្នកអាចហៅទូរស័ព្ទទៅ **មជ្ឈមណ្ឌលព័ត៌មានថ្នាំបង្ការរបស់នាយកដ្ឋានសុខភាពសាធារណៈ (DPH)** តាមរយៈលេខ **833-540-0473** ដែលមានបម្រើការជូន 7 ថ្ងៃក្នុងមួយសប្តាហ៍ ចាប់ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 8:30 យប់។ ពួកគេអាចរៀបចំការចាក់ថ្នាំបង្ការនៅតាមផ្ទះ ការដឹកជញ្ជូនទៅកាន់ទីតាំងចាក់ថ្នាំបង្ការដោយឥតគិតថ្លៃ ឬជួយរៀបចំមធ្យោបាយដឹកជញ្ជូននិងសេវាកម្មផ្សេងទៀតសម្រាប់ជនពិការផងដែរ។ ព័ត៌មានក៏អាចរកបានជាច្រើនភាសា 24 ម៉ោងក្នុងមួយសប្តាហ៍ (24/7) ដោយទូរស័ព្ទទៅកាន់លេខ 2-1-1។

### តើខ្ញុំនឹងត្រូវចំណាយប្រាក់ដើម្បីទទួលបានថ្នាំបង្ការជំងឺ COVID-19 ដែរឬទេ?

ទេ។ ប្រសិនបើអ្នកមានធានារ៉ាប់រង គ្រូពេទ្យឬឱសថស្ថានរបស់អ្នក អាចគិតថ្លៃពីក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នកសម្រាប់ការផ្តល់ថ្នាំបង្ការ។ មនុស្សដែលមិនមានធានារ៉ាប់រងសុខភាព អាចចាក់ថ្នាំបង្ការជំងឺ COVID-19 ដោយឥតគិតថ្លៃផងដែរ។ មិនមានការចំណាយប្រាក់ចេញពីហោប៉ៅផ្ទាល់នោះទេ សម្រាប់បុគ្គលណាក៏ដោយ។

### តើគេនឹងសាកសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់ខ្ញុំ នៅពេលខ្ញុំទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែរឬទេ?

ទេ។ ថ្នាំបង្ការជំងឺ COVID-19 កំពុងត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃ ហើយដោយមិនគិតអំពីស្ថានភាពអន្តោប្រវេសន៍ឡើយ។ អ្នកនឹងមិនត្រូវបានសាកសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកនោះទេ នៅពេលអ្នកទៅទទួលចាក់ថ្នាំបង្ការជំងឺ COVID-19។ ព័ត៌មានផ្នែកវេជ្ជសាស្ត្ររបស់អ្នកគឺរក្សាជាការសម្ងាត់ ហើយការទទួលចាក់ថ្នាំបង្ការ COVID-19 មិនប៉ះពាល់ដល់សានភាពអន្តោប្រវេសន៍របស់អ្នកទេ។ អ្នកមិនត្រូវការប័ណ្ណសម្គាល់ខ្លួនដែលបានចេញដោយរដ្ឋាភិបាល ឬក៏លិខិតពីម្ចាស់អាជីវកម្មឬកន្លែងការងាររបស់អ្នកដើម្បីទទួលថ្នាំបង្ការទេ។ សម្រាប់សំណួរផ្នែកអន្តោប្រវេសន៍ សូមចូលទៅកាន់គេហទំព័ររបស់ការិយាល័យកិច្ចការជនអន្តោប្រវេសន៍តាមរយៈ៖ oia.lacounty.gov ឬទូរស័ព្ទទៅកាន់លេខ 800-593-8222។

### តើខ្ញុំត្រូវផ្តល់លេខទូរស័ព្ទចល័ត ឬអាស័យដ្ឋានអ៊ីម៉ែល ដែរឬទេ?

ទេ។ នៅពេលអ្នកទទួលចាក់ថ្នាំបង្ការ អ្នកនឹងត្រូវបានស្នើសុំឱ្យផ្តល់អាស័យដ្ឋានអ៊ីម៉ែល ឬលេខទូរស័ព្ទចល័ត។ ព័ត៌មាននេះនឹងត្រូវបញ្ចូលទៅក្នុងបញ្ជីឈ្មោះការចាក់ថ្នាំបង្ការទូទៅរបស់រដ្ឋកាលីហ្វ័រញ៉ា (CAIR) ដូច្នេះអ្នកអាចទទួលបានកំណត់ត្រានៃការចាក់ថ្នាំបង្ការជំងឺ COVID-19 ជាលក្ខណៈឌីជីថលបាន។ វាក៏អាចត្រូវបានប្រើប្រាស់ដើម្បីផ្ញើការរំលឹក ប្រសិនបើដល់ពេលកំណត់ ឬត្រូវបានណែនាំឱ្យមកទទួលដូសនៃថ្នាំបង្ការជំងឺ COVID-19 បន្ថែមទៀត។ កំណត់ត្រានៃការចាក់ថ្នាំបង្ការលក្ខណៈឌីជីថល គឺជាមធ្យោបាយដោយឥតគិតថ្លៃ និងងាយស្រួលដើម្បីបញ្ជាក់អំពីស្ថានភាពនៃការចាក់ថ្នាំបង្ការរបស់អ្នក។ វាមានផលប្រយោជន៍ជាពិសេស ប្រសិនបើអ្នកបាត់បង់កាតចាក់ថ្នាំបង្ការពណ៌សរបស់អ្នក។ អ្នកមិនចាំបាច់ផ្តល់អាស័យដ្ឋានអ៊ីម៉ែល ឬលេខទូរស័ព្ទផ្ទាល់ខ្លួនរបស់អ្នកដើម្បីទទួលចាក់ថ្នាំបង្ការ ហើយនិងទទួលកាតចាក់ថ្នាំបង្ការពណ៌ស របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) នោះទេ។ ប៉ុន្តែ ការធ្វើបែបនេះអាចធ្វើឱ្យមានការពិបាកក្នុងការទទួលបានកំណត់ត្រានៃការថ្នាំបង្ការលក្ខណៈឌីជីថលនៅពេលក្រោយ។ អ្នកអាចស្វែងយល់បន្ថែមអំពីកំណត់ត្រានៃការថ្នាំបង្ការលក្ខណៈឌីជីថល តាមរយៈគេហទំព័រ៖ myvaccinerecord.cdph.ca.gov និងអំពីការរក្សាការសម្ងាត់ នៅទីនេះ។

### តើខ្ញុំអាចទទួលបានច្បាប់ចម្លងនៃកំណត់ត្រាការចាក់ថ្នាំបង្ការរបស់ខ្ញុំនៅទីណា?

កាតកំណត់ត្រានៃការចាក់ថ្នាំបង្ការជំងឺ COVID-19 របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC) (កាតពណ៌ស) គឺជាភ័ស្តុតាងផ្លូវការនៃការចាក់ថ្នាំបង្ការ។ មនុស្សគ្រប់រូបគួរតែទទួលបានកាតនេះមួយ នៅពេលពួកគេទទួលចាក់ថ្នាំបង្ការ។ **សូមរក្សាទុកឱ្យមានសុវត្ថិភាព ព្រោះមិនអាចមានកាតជំនួសបានឡើយ។** គួរពិចារណាថតរូប ឬថតចម្លងវាទុក។

មនុស្សគ្រប់រូប* ដែលបានចាក់ថ្នាំបង្ការនៅរដ្ឋកាលីហ្វ័រញ៉ា អាចស្នើសុំកំណត់ត្រានៃការចាក់ថ្នាំបង្ការជំងឺ COVID-19 លក្ខណៈឌីជីថល តាមរយៈគេហទំព័រ myvaccinerecord.cdph.ca.gov។ នេះក៏ជាកំណត់ត្រាផ្លូវការផងដែរ។ អាច

ទាញយកវាបានសម្រាប់កាបូបឌីជីថលរបស់កម្មវិធី Google Pay នៅលើទូរស័ព្ទប្រភេទ Android ឬក៏កម្មវិធី Apple Health នៅលើទូរស័ព្ទម៉ាក iPhone។ អ្នកក៏អាចថតផ្ទៃអេក្រង់ (screenshot) នៃកំណត់ត្រានៃការចាក់ថ្នាំបង្ការជំងឺ COVID-19 លក្ខណៈឌីជីថលរបស់អ្នក ហើយរក្សាវាទុកទៅក្នុងប្រអប់រក្សារូបភាពក្នុងទូរស័ព្ទរបស់អ្នកបាន។ អ្នកអាចទទួលបានកំណត់ត្រាសម្រាប់មនុស្សម្នាក់ៗនៅក្នុងក្រុមគ្រួសាររបស់អ្នក បើទោះបីជាអ្នកបានប្រើប្រាស់អាស័យដ្ឋានអ៊ីម៉ែល ឬលេខទូរស័ព្ទដូចគ្នានៅពេលពួកគេបានទទួលចាក់ថ្នាំបង្ការក៏ដោយ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ កំណត់ត្រានៃការចាក់ថ្នាំបង្ការ។

*ប្រសិនបើអ្នកត្រូវបានផ្តល់ការចាក់ថ្នាំបង្ការដោយទីភ្នាក់ងាររបស់រដ្ឋាភិបាល (ឧទាហរណ៍ ក្រសួងការពារជាតិ សេវាកម្មសុខភាពជនជាតិដើមឥណ្ឌា ឬកិច្ចការអតីតយុទ្ធជន/Department of Defense, Indian Health Service or Veterans Affairs) អ្នកត្រូវតែស្នើសុំកំណត់ត្រានៃការចាក់ថ្នាំបង្ការពីទីភ្នាក់ងារនោះដោយផ្ទាល់តែម្តង។

## តើខ្ញុំត្រូវផ្តល់ការអនុញ្ញាតដើម្បីឱ្យកូនរបស់ខ្ញុំអាចចាក់ថ្នាំបង្ការបាន មែនឬទេ?

យុវវ័យដែលមានអាយុក្រោម 18 ឆ្នាំត្រូវមានការអនុញ្ញាតពីឪពុកម្តាយ/អាណាព្យាបាល ឬអ្នកផ្តល់ការថែទាំ ដើម្បីទទួលចាក់ថ្នាំបង្ការ។ ប្រសិនបើអ្នកមិនអាចមានវត្តមានទេ អ្នកអាចផ្តល់ការអនុញ្ញាតតាមទូរស័ព្ទ វីដេអូ ឬជាលាយលក្ខណ៍អក្សរបាន។ សូមពិនិត្យមើលតម្រូវនៃការអនុញ្ញាតនៅតាមទីតាំងដែលអ្នកមានគម្រោងនឹងទៅ។ ប្រសិនបើនោះជាទីតាំងដែលគ្រប់គ្រងដោយសុខភាពសាធារណៈ (Public Health) អ្នកអាចរកមើលតម្រូវការផ្សេងៗ និងទាញយកបែបបទនៃការអនុញ្ញាតតាមរយៈគេហទំព័រ ph.lacounty.gov/vaccineappointment – ដោយចុចលើ 'ការត្រៀមខ្លួនសម្រាប់ដំណើរទៅរបស់អ្នក (Preparing for your visit)" ឬ ហៅទូរស័ព្ទទៅមជ្ឈមណ្ឌលព័ត៌មានថ្នាំបង្ការ តាមរយៈលេខ 1-833-540-0473 (បម្រើការចាប់ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 8:30 យប់ ជារៀងរាល់ថ្ងៃ)។

ករណីលើកលែងមួយចំនួននឹងត្រូវអនុវត្ត។ អនីតិជន (ជនមិនទាន់គ្រប់អាយុ) ដែលមានអាយុចាប់ពី 15 ឆ្នាំឡើងទៅ ហើយដែលអាចទទួលខុសត្រូវដោយខ្លួនឯងបាន (ឧទាហរណ៍ អនីតិជនដែលមានសិទ្ធិស្របច្បាប់ឬដែលអាចទទួលខុសត្រូវដោយខ្លួនឯង បានរៀបការរួចហើយ ឬធ្លាប់បានរៀបការពីពេលមុន) អាចផ្តល់ការអនុញ្ញាតដោយខ្លួនឯងបាន។ ប្រសិនបើអ្នកជាអ្នកចិញ្ចឹមមើលថែ ជាសាច់ញាតិមើលថែទាំ ឬជាបុគ្គលិកកម្មវិធីព្យាបាលឱ្យស្នាក់នៅរយៈពេលខ្លី (STRTP) អ្នកអាចផ្តល់ការអនុញ្ញាតបាន ដរាបណាកុមារចិញ្ចឹមនោះយល់ព្រម។ ប្រសិនបើអ្នកគឺជាអ្នកចិញ្ចឹមមើលថែ ហើយអ្នកមិនផ្តល់ការអនុញ្ញាតទេ ប៉ុន្តែកូនចិញ្ចឹមរបស់អ្នកចង់ចាក់ថ្នាំបង្ការ ពួកគេអាចទាក់ទងទៅអ្នកប្រឹក្សាខាងច្បាប់របស់ពួកគេបាន។

## តើខ្ញុំត្រូវការយកឯកសារអ្វីខ្លះទៅជាមួយ ដើម្បីចាក់ថ្នាំបង្ការសម្រាប់កូនរបស់ខ្ញុំ?

ទីតាំងចាក់ថ្នាំបង្ការមួយចំនួនអាចតម្រូវចាំបាច់ឱ្យមានប័ណ្ណសម្គាល់ខ្លួនដែលមានរូបថត។ ប្រសិនបើអ្នកជាអាណាព្យាបាលរបស់កុមារដែលស្ថិតក្រោមការចិញ្ចឹមមើលថែទាំ ហើយកូនចិញ្ចឹមរបស់អ្នកមិនមានប័ណ្ណសម្គាល់ខ្លួនដែលមានរូបថតទេនោះ សូមឱ្យពួកគេទាក់ទងទៅអ្នកប្រឹក្សាខាងច្បាប់របស់ពួកគេ។ ជម្រើសមួយទៀត គឺត្រូវទៅកាន់ទីតាំងដែលគ្រប់គ្រងដោយនាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles ដែលមិនតម្រូវឱ្យមានប័ណ្ណសម្គាល់ខ្លួនដែលមានរូបថតទេនោះ។

សូមមើលផ្នែកខាងលើ សម្រាប់ព័ត៌មានអំពីការអនុញ្ញាត។ សូមពិនិត្យមើលតម្រូវការនៃទីតាំងដែលអ្នកមានគម្រោងនឹងទៅ។ ព័ត៌មានទាំងនេះអាចរកបាននៅលើគេហទំព័ររបស់ពួកគេ ឬក៏នៅក្នុងអ៊ីម៉ែលឬសារជាអក្សរដែលបញ្ជាក់អំពីការណាត់ជួបនោះ។ សម្រាប់ព័ត៌មានអំពីតម្រូវការនៅតាមទីតាំងចាក់ថ្នាំបង្ការរបស់នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី LA សូមចូលទៅកាន់គេហទំព័រ ph.lacounty.gov/vaccineappointment - ដោយចុចលើ "ការត្រៀមខ្លួនសម្រាប់ដំណើរទៅរបស់អ្នក (preparing for your visit)" ឬហៅទូរស័ព្ទទៅមជ្ឈមណ្ឌលព័ត៌មានថ្នាំបង្ការ តាមរយៈលេខ 1-833-540-0473 (បម្រើការជូនចាប់ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 8:30 យប់ ជារៀងរាល់ថ្ងៃ)។

## តើខ្ញុំគួរតែទទួលចាក់ថ្នាំបង្ការដែរឬទេ ប្រសិនបើខ្ញុំធ្លាប់មានជំងឺ COVID-19 រួចហើយនោះ?

ចាស/បាទ។ អ្នកគួរតែទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 បើទោះបីជាអ្នកធ្លាប់មានជំងឺ COVID-19 រួចហើយក៏ដោយ។ ការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ក្រោយពេលអ្នកជាបានសះស្បើយពីការឆ្លងជំងឺ COVID-19 ផ្តល់នូវប្រព័ន្ធការពារប្រឆាំងនឹងជំងឺ COVID-19 បន្ថែមទៀត។

ការឆ្លងជំងឺ COVID-19 ផ្តល់នូវប្រព័ន្ធការពារខ្លះពីការធ្លាក់ខ្លួនឈឺដោយសារជំងឺ COVID-19 នាពេលអនាគត

ដែលពេលខ្លះត្រូវបានហៅថា "ប្រព័ន្ធភាពស៊ាំដោយធម្មជាតិ"។ កម្រិតនៃប្រព័ន្ធការពារដែលមនុស្សទាំងឡាយទទួលបានតាមរយៈការឆ្លងជំងឺ COVID-19 អាចប្រែប្រួលអាស្រ័យទៅលើថា តើជំងឺរបស់ពួកគេមានកម្រិតស្រាលឬធ្ងន់ធ្ងរ ពេលវេលាចាប់តាំងពីការឆ្លងមេរោគនោះ និងអាយុរបស់ពួកគេ។ បច្ចុប្បន្ននេះមិនមានការធ្វើតេស្តដែលអាចកំណត់យ៉ាងត្រឹមត្រូវបានថា តើមនុស្សម្នាក់ត្រូវបានការពារពីការឆ្លងឬអត់នោះទេ។

វាមានសុវត្ថិភាពក្នុងការទទួលចាក់ថ្នាំបង្ការបន្ទាប់ពីមានជំងឺ COVID-19 ហើយ ប៉ុន្តែអ្នកគួរតែរង់ចាំរហូតដល់ក្រោយពេលអ្នកបានជាសះស្បើយពីជំងឺនេះ (ប្រសិនបើអ្នកមានរោគសញ្ញា) ហើយរយៈពេលនៃការដាក់ខ្លួនឱ្យនៅដាច់ដោយឡែករបស់អ្នកបានបញ្ចប់។ ការធ្វើដូច្នេះគឺដើម្បីកុំឱ្យអ្នកចម្លងមេរោគទៅកាន់បុគ្គលិកផ្នែកថែទាំសុខភាព និងអ្នកដទៃនៅពេលអ្នកទៅទទួលចាក់ថ្នាំបង្ការ។

ប្រសិនបើអ្នកដល់ពេលកំណត់អាចទទួលចាក់ថ្នាំបង្ការ ហើយបានឆ្លងមេរោគនាពេលថ្មីៗនេះ អ្នកអាចជ្រើសរើសពន្យាពេលចាក់ដូស (ទាំងលំដាប់ដំបូង ឬជំរុញ)រយៈពេល 3 ខែបន្ទាប់ពីការឆ្លងមេរោគនេះ។ នេះក៏ព្រោះតែការសិក្សាថ្មីៗនេះបានបង្ហាញថាការបង្កើនពេលវេលារវាងការឆ្លងមេរោគនិងការចាក់ថ្នាំបង្ការរបស់អ្នក អាចធ្វើឱ្យការឆ្លើយតបនៃប្រព័ន្ធភាពស៊ាំរបស់អ្នកប្រសើរឡើង។ ដូចគ្នានេះផងដែរ ដោយសារតែមានកម្រិតហានិភ័យទាបជាងមុននៃការឆ្លងមេរោគឡើងវិញ ក្នុងអំឡុងពេលជាច្រើនសប្ដាហ៍រហូតទៅដល់ជាច្រើនខែ បន្ទាប់ពីការឆ្លងមេរោគរបស់អ្នក។

ប្រសិនបើអ្នកធ្លាក់ខ្លួនឈឺដោយមានរោគសញ្ញានៃការរលាកពហុសរីរាង្គចំពោះកុមារ ឬមនុស្សពេញវ័យ (MIS-C ឬ MIS-A) សូមពិភាក្សាជាមួយគ្រូពេទ្យរបស់អ្នក មុនពេលទទួលចាក់ថ្នាំបង្ការជំងឺ COVID-19។

## តើខ្ញុំអាចចាក់ថ្នាំបង្ការជំងឺ COVID-19 ក្នុងពេលតែមួយជាមួយនឹងថ្នាំបង្ការផ្សេងទៀតបានដែរឬទេ?

ចាស/បាទ។ មនុស្សពេញវ័យ និងកុមារដែលមានអាយុចាប់ពី 5 ឆ្នាំឡើងទៅ អាចចាក់ថ្នាំបង្ការជំងឺ COVID-19 បានក្នុងពេលជាមួយនឹងថ្នាំបង្ការដទៃទៀត ដូចជាជំងឺកញ្ជ្រឹល ជំងឺក្អកមាន់ និងជំងឺផ្តាសាយធំ។ ប្រសិនបើកូនរបស់អ្នកចាក់ថ្នាំបង្ការជំងឺ COVID-19 នៅកន្លែងដែលមិនផ្ដល់ថ្នាំបង្ការផ្សេងទៀតដែលពួកគេត្រូវការ អ្នកអាចទៅកាន់ទីតាំងផ្សេងដើម្បីចាក់ថ្នាំបង្ការនោះនៅពេលណាក៏បាន។ មិនចាំបាច់រង់ចាំចាក់ថ្នាំបង្ការផ្សេងគ្នាទេ។

## តើខ្ញុំអាចទទួលបាននីតិវិធីវេជ្ជសាស្ត្រ ឬការធ្វើតេស្តត្រួតពិនិត្យតាមទម្លាប់បានដែរឬទេ ប្រសិនបើខ្ញុំទើបតែចាក់ថ្នាំបង្ការជំងឺ COVID-19?

នីតិវិធីវេជ្ជសាស្ត្រ ឬការត្រួតពិនិត្យជំងឺតាមទម្លាប់ភាគច្រើនអាចធ្វើទៅបានមុន ឬក្រោយពេលចាក់ថ្នាំបង្ការជំងឺ COVID-19។

កំណត់សម្គាល់៖ ប្រសិនបើអ្នកដល់ពេលកំណត់ត្រូវថតឆ្លុះសុដន់តាមទម្លាប់ និងបានចាក់ថ្នាំបង្ការជំងឺ COVID-19 នាពេលថ្មីៗនេះ សូមសាកសួរគ្រូពេទ្យរបស់អ្នកថាតើអ្នកគួរតែរង់ចាំរយៈពេលប៉ុន្មានមុនពេលដែលអ្នកអាចថតឆ្លុះនេះបាន។ មនុស្សដែលចាក់ថ្នាំបង្ការជំងឺ COVID-19 អាចនឹងមានហើមកូនកណ្ដុរ (ហៅថា lymphadenopathy) នៅក្លៀកជិតកន្លែងដែលពួកគេបានចាក់ថ្នាំ។ ការហើមនេះគឺជាសញ្ញាធម្មតាដែលថារាងកាយកំពុងកសាងប្រព័ន្ធការពារប្រឆាំងនឹងជំងឺ COVID-19។ ការហើមជាបណ្ដោះអាសន្ននេះអាចបណ្ដាលឱ្យមានការពិនិត្យមើល ការថតឆ្លុះសុដន់មិនត្រឹមត្រូវ ដូច្នេះវាចាំបាច់ក្នុងការប្រាប់ទៅបុគ្គលិកអំពីការចាក់ថ្នាំបង្ការរបស់អ្នក។ សម្រាប់ព័ត៌មានលម្អិតសូមមើល [ដំបូន្មានសម្រាប់ស្ត្រីដែលទទួលថ្នាំបង្ការជំងឺ COVID-19] របស់សមាគមន៍ការថតឆ្លុះសុដន់ (Society of Breast Imaging)។

ថ្នាំបង្ការជំងឺ COVID-19 ក៏អាចប៉ះពាល់ដល់លទ្ធផលនៃការធ្វើតេស្តស្វែងរកជំងឺរបេង (TB) មួយចំនួនផងដែរ សូមមើលគេហទំព័រ [ការចាក់ថ្នាំបង្ការជំងឺ COVID-19 និងនីតិវិធីវេជ្ជសាស្ត្រផ្សេងទៀត] របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។

## តើខ្ញុំគួររៀបចំយ៉ាងដូចម្ដេចសម្រាប់ការទៅតាមការណាត់ជួបរបស់ខ្ញុំ ដើម្បីទទួលចាក់ថ្នាំបង្ការ?

- ចូរចងចាំថាត្រូវនាំយកឯកសារដែលតម្រូវចាំបាច់ ព្រមទាំងអាសយដ្ឋានអ៊ីម៉ែល ឬលេខទូរស័ព្ទចល័តរបស់អ្នក ប្រសិនបើអ្នកមាន។ ប្រសិនបើអ្នកបានធ្វើការណាត់ជួប សូមអានព័ត៌មាននៅក្នុងអ៊ីម៉ែលដែលបញ្ជាក់អំពីការណាត់ជួបនេះ។ ប្រសិនបើអ្នកមានសំណួរផ្សេងៗ វាអាចមានប្រយោជន៍ដោយកត់ត្រាសំណួរទាំងនោះ។

- អ្នកគួរតែទទួលបានឯកសារព័ត៌មានការពិតជាក្រដាសឬជាឯកសារអេឡិចត្រូនិច ដែលប្រាប់អ្នកបន្ថែមទៀតអំពីថ្នាំបង្ការជំងឺ COVID-19 ជាក់លាក់ដែលអ្នកនឹងទៅទទួលចាក់។ ប្រភេទថ្នាំបង្ការជំងឺ COVID-19 ដែលបានទទួលការអនុម័ត និងបានទទួលការអនុញ្ញាតឱ្យប្រើប្រាស់នីមួយៗ មានឯកសារព័ត៌មានការពិតនៃថ្នាំបង្ការនោះរៀងៗខ្លួន ដើម្បីជួយអ្នកក្នុងការស្វែងយល់អំពីហានិភ័យនិងអត្ថប្រយោជន៍នៃការទទួលចាក់ថ្នាំបង្ការជាក់លាក់នោះ។ សូមស្វែងយល់បន្ថែមអំពី ថ្នាំបង្ការជំងឺ COVID-19 ផ្សេងៗគ្នា។
- គ្រោងនឹងស្ថិតនៅកន្លែងណាត់ជួបរហូតដល់រយៈពេលមួយម៉ោង។ នេះរួមបញ្ចូលទាំងរយៈពេលចំនួន 15 ទៅ 30 នាទីសម្រាប់សង្កេតមើលអ្នក បន្ទាប់ពីអ្នកបានទទួលចាក់ថ្នាំបង្ការរបស់អ្នករួចហើយ។
- កុំបញ្ឈប់ការលេបថ្នាំតាមទម្លាប់របស់អ្នក មុនពេលទទួលចាក់ថ្នាំបង្ការ លើកលែងតែគ្រូពេទ្យរបស់អ្នកណែនាំឱ្យអនុវត្តដូច្នេះ។
- មិនមានការណែនាំឱ្យអ្នកលេបថ្នាំដែលមិនចាំបាច់មានវេជ្ជបញ្ជា (ដូចជា ថ្នាំ Ibuprofen ថ្នាំ Aspirin ឬថ្នាំ Acetaminophen) មុនពេលទទួលចាក់ថ្នាំបង្ការ ដើម្បីព្យាយាមទប់ស្កាត់ផលប៉ះពាល់ទាក់ទងនឹងថ្នាំបង្ការនោះទេ។ របៀបដែលថ្នាំទាំងនេះអាចប៉ះពាល់ដល់ប្រសិទ្ធិភាពនៃថ្នាំបង្ការកម្រិតណានោះ គឺមិនទាន់បានដឹងទេ។ ប្រសិនបើអ្នកលេបថ្នាំទាំងនេះជាទៀងទាត់សម្រាប់ហេតុផលផ្សេងទៀត អ្នកគួរតែបន្តលេបថ្នាំទាំងនេះ មុនពេលអ្នកទទួលចាក់ថ្នាំបង្ការ។ ក៏មិនមានការណែនាំឱ្យអ្នកប្រើប្រាស់ថ្នាំប្រឆាំងនឹងប្រតិកម្មឬការទាស់ (antihistamines) មុនពេលទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដើម្បីព្យាយាមទប់ស្កាត់ប្រតិកម្មឬការទាស់នោះដែរ។
- ចូរពាក់ ម៉ាស់ និងសម្លៀកបំពាក់ដែលអាចអនុញ្ញាតឱ្យមានភាពងាយស្រួលក្នុងការចាក់ថ្នាំបង្ការនៅត្រង់ដើមដៃរបស់អ្នក។ សូមពិសាអាហារសម្រន់បន្តិចបន្តួច មុនពេលទៅតាមការណាត់ជួបរបស់អ្នក ហើយរក្សាជាតិទឹក (យកទឹកបន្ថែម ក្នុងករណីត្រូវការពិសា)។
- ប្រសិនបើអ្នកត្រូវការចាក់ថ្នាំបង្ការជំងឺ COVID-19 មួយដូសទៀត ត្រូវប្រាកដថាអ្នកដឹងអំពីរបៀប និងពេលវេលាណាដើម្បីទទួលចាក់ មុនពេលអ្នកចាកចេញពីទីតាំងចាក់ថ្នាំបង្ការនោះ។

## តើខ្ញុំអាចទទួលបានព័ត៌មានបន្ថែមនៅទីណា?

- ដើម្បីបោះពុម្ព ឬមើលសំណួរដែលបានសួរជាញឹកញាប់នេះ ឬសំណួរដែលបានសួរជាញឹកញាប់ផ្សេងទៀតទាក់ទងនឹងប្រធានបទថ្នាំបង្ការជំងឺ COVID-19 សូមស្កេនកូដ QR នេះ ឬចូលទៅកាន់គេហទំព័រ សំណួរដែលបានសួរជាញឹកញាប់ទាក់ទងនឹងថ្នាំបង្ការជំងឺ COVID-19។
- គេហទំព័រ VaccinateLACounty.com - រួមទាំងគេហទំព័រ កាលវិភាគនៃការចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលមានរូបភាពក្រាហ្វិចដើម្បីបង្ហាញនូវពេលណាដែលដូសនីមួយៗដល់ពេលកំណត់អាចទទួល និងព័ត៌មានស្តីពី វិធីទទួលចាក់ថ្នាំបង្ការ។
- គេហទំព័រការទទួលចាក់ ថ្នាំបង្ការជំងឺ COVID-19 របស់មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)។
- ចូរពិគ្រោះជាមួយគ្រូពេទ្យរបស់អ្នក ប្រសិនបើអ្នកមានសំណួរផ្សេងៗ។